ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ
លេខ ៦/១ ន.៣

# សេចក្តីប្រកាសព័ត៌មាន

ក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា សូមសម្តែងការសោកស្តាយ ប្រានចោល និងថ្កោលទោស យ៉ាងដាច់អហង្កា ចំពោះទង្វើដ៏គគ្លើន របស់ក្រសួងរតនាគារ នៃសហរដ្ឋអាមេរិក ដែលបានសម្រេចដាក់ទណ្ឌកម្ម ដោយបង្កកទ្រព្យសម្បត្តិ មកលើមន្ត្រីជាន់ខ្ពស់១រូប នៃកងយោធពលខេមរភូមិន្ទ របស់ប្រទេសកម្ពុជា។

ការសម្រេចដាក់ទណ្ឌកម្មបង្កកទ្រព្យសម្បត្តិមកលើមន្ត្រីជាន់ខ្ពស់កម្ពុជាបែបនេះ គឺជាការរំលោភដល់ច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា ដែលជារដ្ឋអធិបតេយ្យមួយ យ៉ាងអយុត្តិធម៌ជាទីបំផុត ហើយគ្មានភស្តុតាងអ្វីទាំងអស់ ការដាក់ទណ្ឌកម្មបង្កកទ្រព្យសម្បត្តិនេះ គឺជាការសម្រេចដ៏ល្ងង់ខ្លៅ ធ្វើឡើងដោយទំនើងចិត្តសហរដ្ឋអាមេរិក ដែលកម្ពុជាមិនអាចទទួលស្គាល់បានឡើយ។

ក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា សូមអំពាវនាវដល់ក្រសួងរតនាគារសហរដ្ឋអាមេរិក ឱ្យបញ្ឈប់ជាបន្ទាន់ នូវការដាក់ទណ្ឌកម្មណាមួយមកលើមន្ត្រីជាន់ខ្ពស់យោធាកម្ពុជា ដោយមិនមានមូលដ្ឋានច្បាស់លាស់បែបនេះ ៕

ថ្ងៃពុធ ១កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ ២០១៨